អង្គការ
ពលកម្ម
អន្តរជាតិ

# សេចក្ដីណែនាំដំបូងសម្រាប់ ឧស្សាហកម្មកាត់ដេរ

## តើអ្វីខ្លះដែលលោកអ្នកត្រូវយល់ដឹង?

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា



# សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត

១- អ្នកមិនត្រូវបង់ប្រាក់ទៅអោយអ្នកណា ដើម្បីទទួលបានការងារធ្វើទេ ។



២- កិច្ចសន្យាការងារ កំណត់ពីសិទ្ធិនិងការទទួលខុសត្រូវរបស់កម្មករនិយោជិត ។



៣- កម្មករនិយោជិត ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។



# សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត

៤- ការងារបន្ថែមម៉ោង គឺធ្វើឡើងដោយស្ម័គ្រចិត្ត ។



៥- គ្មាននរណាម្នាក់អាចបើកប្រាក់ឈ្នួលជំនួសអ្នកបានទេ វៀរលែងតែអ្នកប្រគល់សិទ្ធិឱ្យ ។



៦- កម្មករនិយោជិត មានសិទ្ធិឈប់សំរាកបុណ្យដោយមានប្រាក់ឈ្នួល ។ កម្មករនិយោជិត មានសិទ្ធិឈប់សំរាកឈឺ អោយតែពួកគេមានសំបុត្រពេទ្យបញ្ជាក់ ។



# សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត

៧- មិនអនុញ្ញាតិអោយលួចសំភារៈរបស់រោងចក្រ ហើយអ្នកនឹងអាចត្រូវបណ្តេញចេញចំពោះការប្រព្រឹត្តនេះ ។



៨- កម្មករនិយោជិត អាចចូលរួម ឬ មិនចូលរួមសហជីព ។ គ្មាននរណាម្នាក់អាចបង្ខំអោយអ្នកចូលជាសមាជិកសហជីព ឬ លាឈប់ពីសហជីពបានទេ ។



# សិទ្ធិ និងការទទួលខុសត្រូវរបស់កម្មករនិយោជិត

៩- អ្នកមានសិទ្ធិឈប់សំរាកលំហែមាតុភាព ៩០ ថ្ងៃ (៣ ខែ) ។ ក្នុងរយៈពេល២ខែដំបូងបន្ទាប់ពីត្រឡប់ចូលធ្វើការវិញក្រោយពេលសំរាកលំហែមាតុភាព និយោជកត្រូវអោយអ្នកធ្វើតែការងារណាដែលស្រាលៗប៉ុណ្ណោះ ។




១០- ប្រសិនបើអ្នកចង់បំបៅដោះកូន អ្នកមានយៈពេល១ម៉ោងក្នុង១ថ្ងៃដែលមានប្រាក់ឈ្នួល សំរាប់បំបៅកូន ។



១១- គ្រប់ទំរង់នៃការបៀតបៀនទាំងអស់ រួមទាំងការបៀតបៀនផ្លូវភេទ ត្រូវហាមឃាត់នៅកន្លែងធ្វើការ ។



១២- ទីកន្លែងធ្វើការត្រូវតែស្អាត ។ និយោជកត្រូវតែផ្តល់គិលានដ្ឋានមួយ ។



១៣- ដើម្បីសុវត្ថិភាព អ្នកត្រូវតែប្រើឧបករណ៍ការពារខ្លួន និង ប្រើឧបករណ៍ការពារម៉ាស៊ីនឱ្យបានត្រឹមត្រូវ ពេលកំពុងធ្វើការ ។



១៤- នៅពេលដែលអ្នកឮសញ្ញាប្រកាសអាសន្ន សូមរក្សាចិត្តឱ្យស្ងប់ និង ដើរសំដៅទៅច្រកចេញដែលនៅជិតអ្នកបំផុត ។



# ការដោះស្រាយវិវាទការងារ

## ១៥- ការចរចា (ជជែកពិភាក្សាគ្នាដើម្បីដោះស្រាយបញ្ហា)



នៅពេលវិវាទការងាររួមកើតឡើង និយោជកនិងកម្មករនិយោជិត ត្រូវចរចាគ្នា ដើម្បីដោះស្រាយបញ្ហា ។

## ១៦- ការផ្សះផ្សា (ជួយភាគីជម្លោះដោះស្រាយបញ្ហា)



ប្រសិនបើនិយោជកនិងកម្មករនិយោជិត មិនអាចដោះស្រាយបញ្ហារបស់ពួកគេបានតាមរយៈការចរចាទេ អ្នកផ្សះផ្សាមកពីក្រសួង នឹងព្យាយាមជួយពួកគេ ។

## ១៧- អាជ្ញាកណ្តាល (ការកាត់សេចក្តីដើម្បីដោះស្រាយវិវាទ)



ប្រសិនបើការផ្សះផ្សាបរាជ័យ វិវាទត្រូវបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងកាត់សេចក្តីដោយផ្អែកតាមច្បាប់ការងារកម្ពុជា ។

## ១៨- កូដកម្មស្របច្បាប់




ប្រសិនបើការដោះស្រាយវិវាទតាមរយៈការចរចា ការផ្សះផ្សា និង អាជ្ញាកណ្តាលបរាជ័យ កម្មករនិយោជិតមានសិទ្ធិធ្វើកូដកម្ម ។

## សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះត្រូវបានរៀបរៀង និង **ផលិតដោយមជ្ឈមណ្ឌលអប់ច្បាប់សម្រាប់សហគមន៍** (CLEC) ។
ម្ចាស់ជំនួយសូមថ្លែងអំណរអរគុណជាពិសេសចំពោះ កញ្ញា អាន វីរៈ (CLEC) កញ្ញា ហេង ឃួឡេង (CLEC) លោក ម៉ៃខល ឡីនីរ (CLEC) និង អ្នកស្រី ហ៊ីយ៉ូណា ជនសុន (ទីប្រឹក្សារបស់ CLEC) ដែលបានខំប្រឹងប្រែងរួមគ្នាក្នុងការផលិតសៀវភៅនេះឡើង ។
អ្នកដែលបានចូលរួមបន្ថែមយោបល់ដល់ការផលិតសៀវភៅនេះឡើង មានអ្នកស្រី ទូ ភារី (ILO គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា) លោកស្រី រ៉ូស ហារីយ (ILO គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា) និង លោក ខននីរ បិយ (ILO គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា) ។

## វិចិត្រគំនូរដោយ

លោក ហូសេ អែនស៊ីណា

## ឧបត្ថម្ភថវិកាដោយ

សៀវភៅនេះត្រូវបានផលិតក្រោមការឧបត្ថម្ភថវិកាតាមរយៈកិច្ចខំប្រឹងប្រែងរួមគ្នានៃធនាគារអភិវឌ្ឍន៍អាស៊ី, ក្រសួងកិច្ចការនារី និង គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជានៃអង្គការពលកម្មអន្តរជាតិ ។

Illustrations & Layout by Jose Encinas jose@tonle.net

ADB ធនាគារអភិវឌ្ឍន៍អាស៊ី

ក្រសួងកិច្ចការនារី